ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

# សេចក្តីប្រកាសព័ត៌មាន

## កម្ពុជា និង ទីម័រខាងកើត ពិភាក្សាអំពីការជំរុញកិច្ចសហប្រតិបត្តិការ

ឯកឧត្តម **ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា បានជួបពិភាក្សាទ្វេភាគីជាមួយលោកជំទាវបណ្ឌិត **អាដាល់ជីហ្សា ហ្សាវីយេ រ៉ៃយ៍ ម៉ាកណូ** (Adaljiza Xavier Reis Magno) រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការ នៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រខាងកើត នៅថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២២ នៅក្នុងឱកាសនៃកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន លើកទី៥៥ និងកិច្ចប្រជុំពាក់ព័ន្ធ នៅរាជធានីភ្នំពេញ។

លោកជំទាវរដ្ឋមន្ត្រីការបរទេស អាដាល់ជីហ្សា ហ្សាវីយេ រ៉ៃយ៍ ម៉ាកណូ បានសម្តែងនូវសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ចំពោះការប្រកាសរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា គាំទ្រការចូលជាសមាជិកអាស៊ានរបស់ប្រទេសទីម័រខាងកើត នៅក្នុងពិធីបើកកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៥៥ និងកិច្ចប្រជុំពាក់ព័ន្ធ។ លោកជំទាវ ក៏បានអបអរសាទរកម្ពុជា ចំពោះភាពជោគជ័យក្នុងការធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំខាងលើ ផងដែរ។

រដ្ឋមន្ត្រីការបរទេសទាំងពីរ បានពិភាក្សាអំពីកាលបរិច្ឆេទសមស្រប និងការត្រៀមរៀបចំសម្រាប់ដំណើរទស្សនកិច្ចផ្លូវរដ្ឋរបស់ប្រធានាធិបតីទីម័រខាងកើតមកកាន់កម្ពុជា និងបានឯកភាពគ្នារៀបចំព្រឹត្តិការណ៍មួយចំនួនដើម្បីអបអរសាទរខួបលើកទី២០ នៃទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរក្នុងឆ្នាំនេះ។ ភាគីទាំងពីរក៏បានសង្កត់ធ្ងន់អំពីតម្រូវការចាំបាច់ក្នុងការធ្វើឱ្យកាន់តែស៊ីជម្រៅនូវទំនាក់ទំនងទ្វេភាគី តាមរយៈកិច្ចពិគ្រោះយោបល់ជាទៀងទាត់ និងការបញ្ចប់ឱ្យឆាប់នូវអនុស្សារណៈនៃការយោគយល់គ្នា (MoU) ស្តីពីកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងទេសចរណ៍។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ប្រាក់ សុខុន** បានគូសបញ្ជាក់អំពីដំណើរការដែលត្រូវអនុវត្តជាបន្តបន្ទាប់ សម្រាប់ការចូលជាសមាជិកអាស៊ានរបស់ទីម័រខាងកើត ក៏ដូចជាការត្រៀមរៀបចំជាចាំបាច់សម្រាប់ការក្លាយជាសមាជិកអាស៊ាន៕

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែសីហា ឆ្នាំ២០២២
អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
**ជុំ សុន្ទរី**

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីមែល : mfaic@mfaic.gov.kh